## ករណីសិក្សាកសិករជោគជ័យឃុំច្បារអំពៅ



កសិករឈ្មោះ សំ សៀ ភេទប្រុស អាយុ ៥៣ឆ្នាំ មានសមាជិកសរុប ៤នាក់ ក្នុងនោះសមាជិកសកម្មក្នុងផលិតកម្មដំណាំស្រូវ ២នាក់។ គាត់ជាកសិកររស់នៅភូមិច្បារអំពៅ ឃុំច្បារអំពៅ ស្រុកបាធាយ ខេត្តកំពង់ចាម។ សព្វថ្ងៃគាត់ប្រកបរបរធ្វើស្រែដែលមានផ្ទៃដីសរុប ៤ហិកតា ពូជស្រូវដែលគាត់ធ្វើការបង្កបង្កើនផលមាន ពូជស្រូវ OM 5451 ជាប្រភេទពូជស្រូវទុកផលិតចេញជាស្រូវចំណី។ ពីការដាំដុះដំណាំស្រូវលោកពូ និងគ្រួសារ បានឆ្លៀតយកពេលវេលាទំនេរបន្តិចបន្តួចធ្វើការដាំដុះដំណាំ បន្លែ ឈើហូបផ្លែ ចិញ្ចឹមសត្វ និងនេសាទត្រីទុកសម្រាប់ការហូបចុកក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ។ ពេលវេលាដាំដុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ និងប្រមូលផលថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៦។

### ១. ការរៀបចំដី

ចំពោះការរៀបចំដី គាត់បានធ្វើការភ្ជួរដីហាលទុកចោលមួយរយៈ និងបញ្ចូលទឹកឱ្យលេច ដោយសារជាប្រភេទដីតំបន់លេចទឹក ។ នៅពេលទឹកចាប់ផ្តើមស្រក់ ដល់ពេលវេលាចុះពូជ គាត់បានបញ្ចេញទឹកចោលខ្លះ ដើម្បីងាយស្រួលក្នុងការរាស់ពង្រាបដី ហើយមានការឆូតកន្លងក្នុងស្រែ តាមការណែនាំរបស់មន្រ្តីកសិកម្មឃុំ។





### ២. ការជ្រើសរើសពូជ



ការជ្រើសរើសពូជ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការដាំដុះដំណាំគ្រប់ប្រភេទទាំងអស់។ ជាពិសេសដំណាំស្រូវក៏ដូចគ្នាដែលលោកពូបានជ្រើសរើសពូជស្រូវ OM 5451 ចំណាត់ថ្នាក់វិញ្ញាបនបត្រ ដែលមានការសម្របសម្រួលដោយ មន្ត្រីកសិកម្មឃុំ។

## ៣.ការសាបព្រោះ

ក្រោយពីបានរៀបចំដីរួចរាល់គាត់បានធ្វើការសាបព្រោះគ្រាប់ពូជស្រូវទៅលើស្រែដែលបានរៀបចំទុក។ ចំពោះទំហំដី ០.៣០ហិចតា គាត់ប្រើប្រាស់ពូជចំនួន ៦០គីឡូក្រាម។





## ៤.ការថែទាំ

### ៤.១. ការប្រើប្រាស់ជី

ការប្រើប្រាស់ជី ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងផលិតកម្មដំណាំស្រូវ ព្រោះការប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស វាជួយឱ្យដំណាំស្រូវដុះលូតលាស់បានល្អ និងទទួលបានទិន្នផលខ្ពស់។ ចំពោះការប្រើប្រាស់ជីក្នុងផលិតកម្មដំណាំស្រូវរបស់គាត់ គាត់បានជ្រើសរើសជី N-P-K និងប្រើប្រាស់ចំនួន ៣លើក ក្នុងមួយវដ្តដំណាំស្រូវតាមការណែនាំរបស់មន្ត្រីកសិកម្មឃុំច្បារអំពៅ។

- លើកទី១ ដំណាក់កាលសំណាប ៖ នៅពេលស្រូវលូតលាស់បានអាយុ ១៥ថ្ងៃ ប្រើប្រាស់ជីចំនួន ៣០គីឡូក្រាម
- លើកទី២ ដំណាក់កាលបែកគុម្ព ៖ នៅពេលស្រូវលូតលាស់បានអាយុ ២៥ថ្ងៃ ប្រើប្រាស់ជីចំនួន ៣០គីឡូក្រាម
- លើកទី៣ ដំណាក់កាលកកើតកួរ ៖ នៅពេលស្រូវលូតលាស់បានអាយុ ៤០ថ្ងៃ ប្រើប្រាស់ជីចំនួន ៣០គីឡូក្រាម





### ៤.២.ការគ្រប់គ្រងទឹក និងគ្រប់គ្រងកត្តាចង្រៃផ្សេងៗ

ចំពោះទឹក ស្រែរបស់គាត់មានទឹកគ្រប់គ្រាន់ ព្រោះមានអណ្តូងទឹកមួយដែលដើរដោយថាមពលសូឡា ដែលអាចគ្រប់គ្រងបាន ហើយស្រែរបស់គាត់មានការបញ្ចេញបញ្ចូលទឹកបានល្អ តាមគោលការណ៍ស្ងួតសើម។ ចំពោះការបំផ្លាញដោយកត្តាចង្រៃផ្សេងៗក៏ពុំសូវឃើញមានវត្តមានឡើយ ដែលយើងសង្កេតឃើញមានត្រឹមតែសត្វទ្រីប នៅដំណាក់កាលសំណាប មូសផ្លុង និងជំងឺបាក់តេរី នៅដំណាក់កាលកំណរកំណើតគួរ។ ពិសេសគាត់បានប្រើប្រាស់ជាមួយទឹកធ្យូងជីវៈ នៅពេលស្រូវស្ថិតក្នុងដំណាក់កាលចេញក្ួរចេញផ្កា ដែលវាមានប្រសិទ្ធភាពជួយការពារការបំផ្លាញពីប្រភេទសត្វជញ្ជក់(ស្រឹងជញ្ជក់ទឹកដោះ និងមមាចត្នោត)។







## ការវិភាគសេដ្ឋកិច្ច

| ល.រ | ប្រភេទចំណាយ | បរិមាណ | ថ្លៃក្នុងមួយឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ១ | ពូជ | ៦០គ.ក/០.៣០ហ.ត | ៣២៥០ | ១៩៥០០០ |
| ២ | ជីគីមី | ២បាវ | ១៤៥០០០ | ២៩០០០០ |
| ៣ | ថ្នាំសម្លាប់សត្វល្អិត | ៣ដង | ១២០០០ | ៣៦០០០ |
| ៤ | ថ្នាំបំប៉ន | ៤ដង | ៦០០០ | ២៤០០០ |
| ៥ | ថ្នាំការពារជំងឺ | ៣ដង | ៦០០០ | ១៨០០០ |
| ៦ | ថ្នាំឃុំគ្រាប់ស្មៅ | ១ដង | ៧០០០ | ៧០០០ |
| ៧ | ប្រេងសាំង និងម៉ាស៊ូត | - | - | ៣០០០០ |
| ៨ | ថ្លៃភ្ជួរ រៀបចំដី | - | - | - |
| ៩ | ថ្លៃជួលអ្នកព្រោះស្រូវ | - | - | - |
| ១០ | ថ្លៃជួលម៉ាស៊ីនច្រូត | - | - | ១១៤០០០ |

| | | | | |
|---|---|---|---|---|
| ១១ | ថ្លៃជួលបាចជី | - | - | - |
| ១២ | ថ្លៃដឹកជញ្ជូន | ២២ការ៉ុង | ២៥០០ | ៥៥០០០ |
| ១៣ | ថ្លៃការ៉ុង និងខ្សែចង | ២២ការ៉ុង | ៥០០ | ១១០០០ |
| ចំណាយសរុប | | | | ៧៨១០០០ |
| ចំណូលសរុប | | ១៥៤០គ.ក/០.៣០ហ.ត | ៧៨០ | ១២០១២០០ |
| ចំណេញសរុប | | | | ៤២០២០០ |

## ចំណុចពិសេសរបស់គាត់

ការរៀបចំដីបានស្អាតល្អ និងមានឆូតគន្លងក្នុងស្រែ

ការប្រើប្រាស់ជីត្រឹមត្រូវតាមដំណាក់កាល (៣ដង)



ការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អ

ការប្រើប្រាស់ទឹកធ្យូងជីវៈថៃទាំនៅដំណាក់កាលស្រូវចេញ

## ៥.ចំណុចប្រៀបធៀប

| ល.រ | ខ្លឹមសារ | ធ្វើតាមទម្លាប់កសិករ | ធ្វើតាមការណែនាំរបស់មន្ត្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | ពូជ | ១០៥គ.ក/០.៣០ហ.ត | ៦០គ.ក/០.៣០ហ.ត | |
| ២ | រៀបចំដី | មិនមានឆូតគន្លង | មានការឆូតគន្លង | |
| ៣ | ជី | ប្រើជី ២បាវ បាច ២ដង | ប្រើជី ២បាវ បាច ៣ដង | |
| ៤ | ទិន្នផល | ១១៩០គ.ក/០.៣០ ហ.ត | ១៥៤០គ.ក/០.៣០ ហ.ត | |

## ៦.សេចក្តីសន្និដ្ឋាន

### ក.ចំណុចបន្ត

- គាត់នៅតែបន្តការរៀបចំដី ដោយពង្រាបដីឱ្យបានស្អាតល្អ និងឆូតគន្លងក្នុងស្រែ
- នៅតែបន្តការប្រើប្រាស់ ៣វគ្គតាមដំណាក់កាលលូតលាស់របស់ដំណាំស្រូវ

– នៅតែបន្តការប្រើប្រាស់គ្រាប់ពូជសុទ្ធ និងគ្រាប់ពូជពេញល្អ។

**ខ.ចំណុចបន្ថែម**

– គាត់និងចាប់ផ្តើមប្រើប្រាស់ជីសរីរាង្គទ្រាប់បាត

– បង្កើនការការប្រាស់ថ្នាំពុលធម្មជាតិ និងទឹកផ្សងជីវៈ ច្រើនវគ្គជាងមុន

**គ.ចំណុចបន្ថយ**

– បន្ថយការប្រើប្រាស់ថ្នាំពុលគីមី

– បន្ថយការប្រើប្រាស់ជីគីមី

**ឃ.ចំណុចបញ្ឈប់**

– បញ្ឈប់ការប្រើប្រាស់ថ្នាំពុលគីមី ជំនួសដោយការប្រើប្រាស់ទឹកផ្សងជីវៈ ជាមួយជីបំប៉នតាមស្លឹក។










ថ្ងៃសៅរ៍ ១២រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

កំពង់ចាម, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៦

**អ្នកធ្វើរបាយការណ៍**



មន្ត្រីកសិកម្មឃុំច្បារអំពៅ រ៉ុម ភក្តី